ប្រទេសចិន-ខេត្តយូណាន
云南日报报业集团 YUNNAN DAILY PRESS GROUP
១២
កោះសន្តិភាព | លេខ ៤៨ ថ្ងៃ សុក្រ ទី ១៤ ខែ មិថុនា ឆ្នាំ ២០២៤
云南省南亚东南亚区域国际传播中心
Yunnan Int'l Communication Center for South and Southeast Asia

ការផ្លាស់ប្តូរ

# យើងទាំងអស់គ្នាជាអ្នកអភិរក្ស





ឆ្នាំនេះគឺជា "ឆ្នាំនៃការផ្លាស់ប្តូរប្រជាជន និងប្រជាជន ចិន-កម្ពុជា"។ នៅថ្ងៃទី៧ ខែមិថុនា ក្នុងឱកាសនៃ "ទិវាបេតិកភណ្ឌវប្បធម៌ និងធម្មជាតិ ឆ្នាំ ២០២៤" កម្មវិធីសំឡេងទីតាំងបេតិកភណ្ឌ "ដើរកម្សាន្តនៅយូណាន ទៅទស្សនានៅអង្គរ" នៃប្រទេសចិន(ខេត្តយូណាន)-ព្រះរាជាណាចក្រកម្ពុជាបានបើកនៅទីក្រុងគុនមីង ខេត្តយូណាននៃប្រទេសចិន។ ដោយផ្អែកលើការការពារ និងការទទួលមរតកនៃបេតិកភណ្ឌពិភពលោក ក្នុងសកម្មភាពនេះត្រូវបានប្រារព្ធធ្វើទស្សនកិច្ចនៅនឹងកន្លែង ការទាញយកបទពិសោធន៍លើប្រធានបទ កិច្ចប្រជុំសន្ទនានិពន្ធនាយកអង្គភាពសារព័ត៌មានចិន-កម្ពុជា និងពិធីផ្សព្វផ្សាយពីខ្សែទេសចរណ៍បេតិកភណ្ឌពិភពលោកជាដើម។ ជំនួបនៃបេតិកភណ្ឌពិភពលោក គឺជាការផ្តោតការយកចិត្តទុកដាក់ពីមនុស្សគ្រប់គ្នា ក៏ជាអារម្មណ៍ដែលកើតចេញពីបេះដូងផងដែរ ការចាប់ដៃគ្នាដើម្បីរៀនសូត្រទៅវិញទៅមកក្នុងចំណោមអរិយធម៌ គឺជាការសន្ទនារវាងវប្បធម៌ផ្សេងៗគ្នា និងជាការផ្លាស់ប្តូរបើកចំហ និងរួមបញ្ចូល។

## "យើងទាំងអស់គ្នាជាអ្នកផ្សព្វផ្សាយ"

កិច្ចសហប្រតិបត្តិការប្រព័ន្ធផ្សព្វផ្សាយកសាងស្ពានសម្រាប់ការផ្លាស់ប្តូរ និងការរៀនសូត្រពីគ្នាទៅវិញទៅមករវាងអរិយធម៌ចិន និងកម្ពុជា។ ក្នុងឱកាសកម្មវិធីនោះ លោកជំទាវ អ៊ូ សៀ សមាជិកក្រុមបក្ស និងជាលេខាធិការនៃលេខាធិការដ្ឋានសមាគមអ្នកកាសែតទូទាំងប្រទេសចិនបានមានប្រសាសន៍ថា សមាគមអ្នកកាសែតចិនលើកទឹកចិត្តឱ្យប្រព័ន្ធផ្សព្វផ្សាយចិន និងកម្ពុជា ពង្រឹងកិច្ចសហប្រតិបត្តិការឱ្យស៊ីជម្រៅ និទានរឿងអំពីកិច្ចសហប្រតិបត្តិការដោយល្អប្រសើរ និងផ្សព្វផ្សាយសំឡេងនៃកិច្ចសហប្រតិបត្តិការដោយមានប្រសិទ្ធភាព។

ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា កម្មវិធីសំឡេងទីតាំងបេតិកភណ្ឌ "ដើរកម្សាន្តនៅយូណាន ទៅទស្សនានៅអង្គរ" នៃប្រទេសចិន(ខេត្តយូណាន)-ព្រះរាជាណាចក្រកម្ពុជា គឺជាការឆ្លុះបញ្ចាំងពិតនៃកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងប្រព័ន្ធផ្សព្វផ្សាយកម្ពុជា និងចិន។ ប្រព័ន្ធផ្សព្វផ្សាយមានតួនាទីសំខាន់ក្នុងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសកម្ពុជា និងខេត្តយូណាននៃប្រទេសចិន។ នៅពេលអនាគត ប្រព័ន្ធផ្សព្វផ្សាយភាគីទាំងពីរអាចពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យដូចជា ការបង្កើតថ្មីបច្ចេកវិទ្យា និងការផ្លាស់ប្តូរឌីជីថលឱ្យស៊ីជម្រៅ រួមគ្នាផ្សព្វផ្សាយព័ត៌មានទេសចរណ៍ លើកកម្ពស់ការអភិវឌ្ឍទេសចរណ៍និងវប្បធម៌ ការពារបេតិកភណ្ឌពិភពលោក និងរួមគ្នាលើកកម្ពស់វឌ្ឍនភាពនៃឧស្សាហកម្មប្រព័ន្ធផ្សព្វផ្សាយ។

ស្របតាមល្បឿននៃសម័យកាល ប្រព័ន្ធផ្សព្វផ្សាយកំពុងខិតខំប្រឹងប្រែងដើម្បីបញ្ចូលថាមពលកាន់តែល្អទៅក្នុងអនាគតរួម។ នៅថ្ងៃដដែលនោះ សម្ព័ន្ធប្រព័ន្ធផ្សព្វផ្សាយអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍បានលើកឡើងពាក្យ "ខ្ញុំជាអ្នកអភិរក្ស" ដែលជាគំនិតផ្តួចផ្តើមការពារបេតិកភណ្ឌធម្មជាតិ និងវប្បធម៌សកលដើម្បីការពារភ្នំនិងទន្លេ ការពារផ្ទះប្រវត្តិសាស្ត្រ និងការពារកំណាព្យនិងកន្លែងឆ្ងាយ។ ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការប្រាស្រ័យទាក់ទងគ្នាក្នុងការការពារបេតិកភណ្ឌវប្បធម៌ និងធម្មជាតិ ការពារភាពស្រស់ស្អាតនៃធម្មជាតិ និងពន្លឺនៃអរិយធម៌មនុស្សរបស់ពិភពលោក និងរួមគ្នាដើម្បីកសាងសហគមន៍ជោគវាសនារួមសម្រាប់មនុស្សជាតិ។

## "ពួកយើងជាអ្នកអភិរក្សដូចគ្នា"



អរិយធម៌ប្រៀបដូចជាទឹក លះបង់ដោយស្ងៀមស្ងាត់ បង្កើតក្តីសង្ឃឹម។ ភ្ញៀវកិត្តិយសក្នុងកិច្ចប្រជុំមានការឯកភាពច្បាស់លាស់ ៖ ការការពារសម្បត្តិវប្បធម៌ និងសម្បត្តិធម្មជាតិរបស់មនុស្សជាតិទាំងអស់ ទាមទារឱ្យមានការទទួលខុសត្រូវរួមគ្នា។

យោងតាមឯកឧត្តម ប្រាក់ ផាន់ណារ៉ា រដ្ឋលេខាធិការក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា "ដើរកម្សាន្តនៅយូណាន ទៅទស្សនានៅអង្គរ" បានភ្ជាប់ទំនាក់ទំនងខេត្តយូណានប្រទេសចិន ជាមួយនឹងប្រទេសកម្ពុជាយ៉ាងជិតស្និទ្ធ ហើយអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរនឹងបញ្ចូលកម្លាំងជំរុញថ្មីក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាក់ស្តែងរវាងប្រទេសកម្ពុជា និងប្រទេសចិន ជាពិសេសខេត្តយូណាន។ ឯកឧត្តម ប្រាក់ ផាន់ណារ៉ា មានប្រសាសន៍ថា នាពេលខាងមុខ យើងសង្ឃឹមថាភាគីទាំងពីរនឹងទាញយកសក្តានុពលរបស់ខ្លួន បំពេញបន្ថែមនូវគុណសម្បត្តិរបស់គ្នាទៅវិញទៅមក អនុវត្តកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ឆ្លាតវៃ និងការវិនិយោគទេសចរណ៍ជាដើម ដើម្បីទាក់ទាញភ្ញៀវទេសចរពីភាគីទាំងសងខាងឱ្យមកទស្សនាកាន់តែច្រើនឡើង និងរួមគ្នាជំរុញការអភិវឌ្ឍវិស័យទេសចរណ៍។

តាមការលើកឡើងរបស់លោក ងួន សេរ័ត្ន អគ្គនាយករងនៃក្រុមហ៊ុនកោះសន្តិភាព ខូអិលធីឌី របស់ប្រទេសកម្ពុជាបានលើកឡើងថា ដើម្បីលើកកម្ពស់ការការពារ និងទទួលមរតកបេតិកភណ្ឌពិភពលោក ពួកយើងនិងមជ្ឈមណ្ឌលមជ្ឈមណ្ឌលផ្សព្វផ្សាយអន្តរជាតិចំពោះតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ បានរួមគ្នាបង្កើតកម្មវិធី "ខ្ញុំជាអ្នកអភិរក្ស" ព្រមទាំងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការលើគម្រោងទំនាក់ទំនងអន្តរជាតិ "ដើរកម្សាន្តនៅយូណាន ទៅទស្សនានៅអង្គរ" ជំរុញផលិតផល "ប្រព័ន្ធផ្សព្វផ្សាយ+" ឱ្យកាន់តែសម្បូរបែប និងកាន់តែពិសេសជាងមុនសម្រាប់ប្រជាជននៃប្រទេសទាំងពីរ។

លោកស្រី តឹង ពីលីង អ្នកទទួលមរតកនៃសិល្បៈបេតិកភណ្ឌវប្បធម៌អរូបីនៃការគូរគំនូរក្លួសុនណេក្នុងទីក្រុងគុនមីងបាននិយាយថា ការផ្លាស់ប្តូរបញ្ចូលនូវជីវិតទៅក្នុងការការពារបេតិកភណ្ឌ។ លោកស្រីរំពឹងថា ភ្ញៀវទេសចរមកពីប្រទេសកម្ពុជា និងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ផ្សេងទៀតមកទស្សនាសិក្ខាសាលាបេតិកភណ្ឌវប្បធម៌អរូបីរបស់លោកស្រី ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងផ្លាស់ប្តូរទៅវិញទៅមក។

កញ្ញា យ៉ង់ សុភក្ត្រា ជាអ្នករបាំមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈកម្ពុជា ឪពុករបស់នាងគឺជាគ្រូបង្រៀនរបាំ ក្រោមឥទ្ធិពលរបស់ឪពុក កញ្ញា យ៉ង់ សុភក្ត្រា បានស្រលាញ់ការរាំតាំងពីនាងនៅក្មេង។ នាងនិយាយថា ដើម្បីការពារសិល្បៈរបាំប្រពៃណី អ្នករបាំវ័យក្មេងត្រូវបញ្ចេញកម្លាំងរបស់ខ្លួន។

## "គ្រួសារខ្ញុំរស់នៅក្នុងតំបន់បេតិកភណ្ឌ"

តើអ្នកដែលរស់នៅក្នុងតំបន់បេតិកភណ្ឌមានរឿងរ៉ាវអភិរក្សបែបណាដែរ? ក្នុងកម្មវិធីនេះ មិត្តដែលមកពីប្រទេសចិន កម្ពុជា និងឡាវ បានចែករំលែកពីរឿងរ៉ាវការពារបេតិកភណ្ឌពិភពលោក។

ដោយសារតែភាពយន្ត ‹‹Coffee or Tea›› លោក PHETSAMONE KHOUNSAVATH គ្រូបង្រៀនភាសាឡាវនៅវិទ្យាស្ថានភូអឺ ជ្រើសរើសមកទីក្រុងភូអឺ មកដល់ភ្នំជីងម៉ៃ។ នៅខែកញ្ញា ឆ្នាំ២០២៣ “ទេសភាពវប្បធម៌ព្រៃតែបុរាណនៃភ្នំជីងម៉ៃនៅភូអឺ” បានក្លាយជាបេតិកភណ្ឌវប្បធម៌ពិភពលោកដែលមានប្រធានបទតែដំបូងគេរបស់ពិភពលោក។ លោក PHETSAMONE KHOUNSAVATH និយាយថា មានរសជាតិមួយប្រភេទហៅថាភូអឺ រសជាតិរបស់ភូអឺមិនត្រឹមតែជារសជាតិនៃតែ និងកាហ្វេប៉ុណ្ណោះទេ ថែមទាំងជារសជាតិនៃការចុះសម្រុងគ្នារវាងមនុស្ស និងធម្មជាតិផងដែរ។

យោងតាមកញ្ញា អ៊ី មឹងអ៊ី "មគ្គុទ្ទេសក៍ទេសចរណ៍មេដាយមាស" របស់ខេត្តយូណាន បានអោយដឹងថា ខេត្តយូណានគឺជាកំណាព្យបែបទេសភាព កំណាព្យបែបនិទានកថា និងជាកំណាព្យបែបមនោសញ្ចេតនា។ នាងបានបន្តនិយាយថា បន្ទាប់ពីបានទៅទស្សនាតំបន់បេតិកភណ្ឌពិភពលោកទាំងប្រាំមួយក្នុងខេត្តយូណាន ទទួលបានអារម្មណ៍ពិសេសពីទំនៀមទម្លាប់ជនជាតិ ភាពស្រស់ស្អាតនៃធម្មជាតិ ភាពទាក់ទាញនៃប្រវត្តិសាស្ត្រ និងភាពរុងរឿងនៃជនជាតិក្នុងខេត្តយូណាន គឺទស្សនា និងដើរកម្សាន្តមិនអស់នោះទេ។

លោក លុយ ណត់ អនុប្រធានសមាគមមគ្គុទេសក៍ទេសចរណ៍ភាសាចិនកម្ពុជាណែនាំថា ដើម្បីឱ្យភ្ញៀវទេសចរណ៍ចិនកាន់តែច្រើនយល់ដឹងពី "ស្នាមញញឹមអង្គរ" សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ភាសាចិនកម្ពុជាបានពង្រឹងសមត្ថភាពអ្នកប្រកបរបរទេសចរណ៍តាមរយៈការសិក្សា ការបណ្តុះបណ្តាល ការរៀននៅនឹងកន្លែង និងវិធីសាស្ត្រផ្សេងៗទៀត។

លោក មូ ជីយាន់ សាស្ត្រាចារ្យនៅសាកលវិទ្យាល័យព្រៃឈើភាគនិរតី ដែលបានប្តេជ្ញាចិត្តក្នុងការការពារបេតិកភណ្ឌពិភពលោក ទីក្រុងបុរាណលីជាំង ខេត្តយូណាន បានបង្ហាញថា ទីក្រុងបុរាណ ផ្លូវបុរាណ និងផ្លូវដើរបុរាណរបស់ក្រុងលីជាំងដែលស្ថិតនៅចន្លោះភ្នំ និងទន្លេ បានទាក់ទាញភ្ញៀវទេសចរមកពីជុំវិញពិភពលោក តាមរយៈការស្វែងយល់ពីការប្រើប្រាស់សេដ្ឋកិច្ចទេសចរណ៍ក្នុងការគាំទ្រដល់ការការពារបេតិកភណ្ឌ បង្កើតបានគំរូលីជាំងសម្រាប់ការការពារ និងអភិវឌ្ឍន៍បេតិកភណ្ឌវប្បធម៌ពិភពលោក ភាពទាក់ទាញនៃ "ទីក្រុងលីជាំង" កាន់តែសម្បូរបែប៕

***អត្ថបទដោយ លាន ជីយូ នាង យួន ទាំង យួនយ៉ា ចាំង មីង***



រូបភាពដោយកាសែតយូណានដេលី ក្រសួងទេសចរណ៍កម្ពុជា និងអ្នកទទួលសម្ភាសន៍

អ្នកនិពន្ធភាសាចិន៖ RAN XIULAN អ្នកនិពន្ធភាសាខ្មែរ៖ LI ZHA SHEN YAN រចនារូបភាព៖ SUN YONGGANG